## សុន្ទរកថា
## របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ថ្លែងក្នុង
## សន្និសីទជាតិស្តីពីទីផ្សារមូលបត្រកម្ពុជា
## «មួយទសវត្សរ៍នៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និង ដំណើរឆ្ពោះទៅមុខ»

នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ និង ប្រព័ន្ធអនឡាញ
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០២២

៙៙✹៚៚

- *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ដែលមានវត្តមាននៅទីនេះផ្ទាល់ និង តាមប្រព័ន្ធអនឡាញ ជាទីមេត្រី!*

ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានចូលរួមធ្វើជាអធិបតីនៅក្នុង សន្និសីទជាតិស្តីពីទីផ្សារមូលបត្រកម្ពុជា ក្រោមប្រធានបទ **«មួយទសវត្សរ៍នៃការ-អភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និង ដំណើរឆ្ពោះទៅមុខ»** ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ សម្រាប់វិស័យមូលបត្រនៅកម្ពុជា ។ ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រីទាំងអស់ ដែលបានចំណាយពេលវេលាអញ្ជើញចូលរួមក្នុងសន្និសីទនេះ ។

ឆ្លៀតឱកាសនេះផងដែរ, ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងការអបអរសាទរ ជាអនេក ចំពោះថ្នាក់ដឹកនាំនៃនិយ័តករមូលបត្រកម្ពុជា និង ផ្សារមូលបត្រកម្ពុជា ដែលរួមមាន៖ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**, ឯកឧត្តម **ស៊ូ សុជាតិ**, ឯកឧត្តម **ហុង សុហួរ** ព្រមទាំងថ្នាក់ដឹកនាំ, បុគ្គលិក និង ភាគីពាក់ព័ន្ធទាំងអស់ ដែលបាន

ខិតខំប្រឹងប្រែងពុះពារជម្នះរាល់ឧបសគ្គ ដើម្បីអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់ដូចសព្វថ្ងៃ និង រំពឹងថា នឹងមានការរីកចម្រើនកាន់តែខ្លាំងក្លាថែមទៀត នាពេលអនាគត ។

តាមទ្រឹស្តីសេដ្ឋកិច្ច, វិស័យមូលបត្រអាចចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការកៀរគរ និង បែងចែកមូលធន ពីភ្នាក់ងារសេដ្ឋកិច្ចដែលមានសមត្ថភាពហិរញ្ញប្បទាន (មានន័យថា មានលទ្ធភាពសន្សំប្រាក់) ជូនទៅភ្នាក់ងារសេដ្ឋកិច្ច ដែលមានតម្រូវការហិរញ្ញប្បទាន ។ វិស័យមូលបត្រដែលរីកចម្រើន នឹងផ្តល់នូវប្រភពទុនមួយដែលមិនចេះរីងស្ងួត សម្រាប់ម្ចាស់អាជីវកម្មជាទូទៅ ហើយបង្កើតឡើងនូវប្រភពចំណូលមួយ សម្រាប់បុគ្គល និង តួអង្គសេដ្ឋកិច្ចផ្សេងទៀត ដែលអាចធ្វើពិពិធកម្មខ្ទង់វិនិយោគរបស់ខ្លួនបានកាន់តែប្រសើរ ។

ក្នុងន័យនេះ, គម្រោងអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា បានចាប់ផ្តើមក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែល**សម្តេច**បានចាត់ឱ្យមានការបង្កើតក្រុមការងារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសិក្សាអំពីលទ្ធភាពនៃការបង្កើតទីផ្សារមូលបត្រនេះឡើង នៅក្នុងឆ្នាំ ២០០៦ ហើយត្រូវបានដឹកនាំផ្ទាល់ដោយ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ តែជារួម, វិស័យមូលបត្រនៅកម្ពុជា ត្រូវបានសន្មតថា បានចាប់ផ្តើមបដិសន្ធិឡើង ជាមួយនឹងការដាក់ឱ្យប្រើនូវច្បាប់ស្តីពីការបោះផ្សាយ និង ជួញដូរមូលបត្រមហាជន ក្នុងឆ្នាំ ២០០៧ និង ការដាក់ឱ្យដំណើរការនូវ **គណៈកម្មការមូលបត្រកម្ពុជា** ក្នុងឆ្នាំ ២០០៨ និង តួអង្គនានាក្នុងវិស័យមូលបត្រជាបន្តបន្ទាប់ ។ ហើយផ្សារមូលបត្រកម្ពុជាវិញ ត្រូវបានបង្កើតឡើងក្រោមរូបភាពជាក្រុមហ៊ុនចម្រុះរដ្ឋ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ ក្នុងឆ្នាំ ២០១០ និង បានបើកដំណើរការជួញដូរមូលបត្រជាលើកដំបូងនៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ ២០១២ ជាមួយនឹងការចុះបញ្ជីជួញដូរមូលបត្ររបស់សហគ្រាសសាធារណៈចំនួនមួយ គឺ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

ដើម្បីអភិវឌ្ឍវិស័យមូលបត្រ, រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសេនាធិការ តែងយកចិត្តទុកដាក់គាំទ្រវិស័យមួយនេះ តាមរយៈការលើក

ទឹកចិត្តពន្ធដារសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និង វិនិយោគិន, ការយកចិត្តទុកដាក់ការពារផលប្រយោជន៍របស់សាធារណជន និង ការរៀបចំបទប្បញ្ញត្តិដែលមានលក្ខណៈអំណោយផល ដល់សកម្មភាពមូលបត្រជាដើម ។ រាជរដ្ឋាភិបាលនឹងនៅបន្តការយកចិត្តទុកដាក់នេះ ក៏ដូចជាការគិតគូរអំពីយន្តការនានាបន្ថែម ដើម្បីឱ្យទីផ្សារមួយនេះ អាចបំពេញតួនាទីបែងចែកមូលធនរបស់ខ្លួន កាន់តែទូលំទូលាយ និង កាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកពន្ធដារ, រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តជាការកាត់បន្ថយពន្ធលើប្រាក់ចំណូល សម្រាប់សហគ្រាសដែលចុះបញ្ជីលក់មូលបត្រ, ទាំងមូលបត្រកម្មសិទ្ធិ និង មូលបត្របំណុល, និង កាត់បន្ថយពន្ធកាត់ទុកលើការប្រាក់លើភាគលាភ និង លើការប្រាក់ពាក់ព័ន្ធនឹងមូលបត្របំណុល តាំងពីទីផ្សារមូលបត្រកម្ពុជាបានចាប់ផ្តើមដំណើរការដំបូង ក្នុងឆ្នាំ ២០១២ រហូតមកដល់បច្ចុប្បន្ន និង នៅតែបន្តការ-លើកទឹកចិត្តបែបនេះ រហូតទាល់តែឈានដល់កម្រិតអភិវឌ្ឍដែលអាចទទួលយកបាន ។

រាជរដ្ឋាភិបាល ក៏គ្រោងនឹងចាប់ផ្តើមបោះផ្សាយមូលបត្ររដ្ឋក្នុងឆ្នាំ ២០២២ នេះ ដើម្បីបង្កើតនូវប្រភពហិរញ្ញប្បទានមួយថ្មី សម្រាប់ការកៀរគរទុនរបស់រដ្ឋ ក៏ដូចជាដើម្បីបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី សម្រាប់វិនិយោគិននៅក្នុងទីផ្សារមូលបត្រ ជាពិសេសវិនិយោគិនស្ថាប័នដូចជា ធនាគារ, ក្រុមហ៊ុនធានារ៉ាប់រង, មូលនិធិសោធនិវត្តន៍, មូលនិធិសន្តិសុខសង្គម ជាដើម ។ ឧបករណ៍ហិរញ្ញវត្ថុថ្មី រំពឹងថានឹងទទួលបានការពេញនិយមសម្រាប់ការជួញដូរនៅក្នុងផ្សារមូលបត្រកម្ពុជា និង ផ្តល់នូវទិន្នន័យ Benchmark សម្រាប់ការជួញដូរមូលបត្រសាជីវកម្ម និង ការវិភាគហិរញ្ញវត្ថុនានា ដូចត្រូវបានអនុវត្តនៅក្នុងប្រទេសដែលមានវិស័យមូលបត្ររីកចម្រើន ។

### ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!

ម្លប់នៃសន្តិភាព ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក គឺជាសមិទ្ធផលមិនអាចកាត់ថ្លៃបាន ដែលត្រូវបាននាំមកជូនប្រជាជន និង ប្រជាជាតិរបស់យើងដោយ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។ ក្រៅពីការកសាងសមិទ្ធផលរូបវន្តជាច្រើនឥតគណនា, រាជរដ្ឋាភិបាលក៏បាន និង កំពុងបន្តខិតខំរៀបចំ និង ដាក់ចេញនូវគោលនយោបាយ និង វិធានការជាបន្តបន្ទាប់ ដើម្បីដោះស្រាយរាល់បញ្ហាប្រឈមនានា, ទាំងក្នុងផ្នែកសេដ្ឋកិច្ច និង សង្គម, សំដៅធានាឱ្យ

បាននូវភាពអំណោយផលនៃបរិយាកាសធុរកិច្ច និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសម្រាប់ទាក់ទាញ វិនិយោគ និង ពាណិជ្ជកម្ម ជាពិសេស សំដៅពន្លឿនការធ្វើពិពិធកម្ម និង ពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា តែងចាត់ទុកវិស័យឯកជនជាដៃគូមិនអាចខ្វះបានរបស់ខ្លួន ។ ក្នុងន័យនេះ, បន្ថែមលើយន្តការផ្សារមូលបត្រដែលជាកម្មវត្ថុនៃសន្និសីទនៅថ្ងៃនេះ, គំនិតផ្តួចផ្តើមជាច្រើនទៀត ត្រូវបានដាក់ឱ្យដំណើរការជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់វិស័យឯកជន មានជាអាទិ៍ៈ ការបង្កើតមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និង មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី **តេជោ** ដើម្បីជួយគាំទ្រដល់អាជីវកម្មបង្កើតថ្មីនានា, ការបង្កើតធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា និងការដាក់ឱ្យដំណើរការ «គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និង មធ្យម», ជាពិសេស ការបង្កើតវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន, ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួលក្នុងការធ្វើធុរកិច្ចនៅកម្ពុជា ។

ជាការពិតណាស់, យើងបានឈានដល់ស្ថានភាពធូរស្បើយពីការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈវិធានការនានា ជាពិសេស គោលនយោបាយជាតិវ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ដ៏មានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និង ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ម៉ត់ចត់, ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាហេតុធ្វើឱ្យកម្ពុជាអាចបើកដំណើរការសង្គម និង សេដ្ឋកិច្ច បានពេញលេញឡើងវិញលើគ្រប់វិស័យ ។ ទោះជាយ៉ាងនេះក្តី, ការលេចឡើងនូវវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីៗជាបន្តបន្ទាប់, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា និង ភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយ ជាពិសេស សង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន គឺជាហានិភ័យចំពោះមុខ ដែលបាន និង កំពុងនាំមកនូវបច្ច័យអវិជ្ជមានយ៉ាងស្រួចស្រាល និង បន្តដាក់សម្ពាធលើមាគ៌ាងើបឡើងវិញ (Recovery pathway) នៃសេដ្ឋកិច្ចសកល តាមរយៈការបង្អាក់នូវដំណើរការតំណភ្ជាប់សំខាន់ៗនៃខ្សែច្រវ៉ាក់ផលិតកម្មសកល និង ការកើនឡើងនូវថ្លៃថាមពល ដែលជាលទ្ធផលបង្កឱ្យមានការកើនឡើងនូវថ្លៃទំនិញគ្រប់ប្រភេទ ។

ស្ថិតក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលបន្តប្តេជ្ញាជំរុញពន្លឿនវឌ្ឍនភាពនៃការអនុវត្តការដ្ឋានកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ សំដៅកសាងប្រព័ន្ធសេដ្ឋកិច្ច និង សង្គម ឱ្យកាន់តែ

រឹងមាំ និង មានភាពធន់ទៅនឹងវិបត្តិនាពេលអនាគត ជាពិសេស ឆ្លើយតបបានទាន់ពេល ទៅនឹងនិន្នាការសំខាន់ៗ និង ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃព្រឹត្តិការណ៍នានា ក្នុងតំបន់ និង សកល ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវ **«ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយនឹងកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីឆ្នាំ ២០២១-២០២៣»** ក្នុងគោលបំណងស្តារសេដ្ឋកិច្ចកម្ពុជា ក្នុងពេលចំពោះមុខ និង ក្នុងរយៈពេលមធ្យម ឱ្យត្រលប់ទៅរកមាគ៌ានៃកំណើនរបស់ខ្លួន និង ពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និង បរិយាប័ន្ន ក្នុងរយៈពេលវែង ដែលក្នុងនោះបានគូសរំលេចអំពីសារៈសំខាន់នៃការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ក្នុងវិស័យសាធារណៈ និង ឯកជន ដើម្បីជំរុញល្បឿននៃការ-ស្តារសេដ្ឋកិច្ចជាតិឱ្យបានលឿន និង ឆាប់រហ័សផងដែរ ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!**

ជាមួយនឹងការកត់សម្គាល់លើការវិវត្តខ្លួនរបស់ផ្សារមូលបត្រកម្ពុជា និង វឌ្ឍភាពសំខាន់ៗក្នុងរយៈពេល ១០ ឆ្នាំកន្លងទៅនេះ ដូចដែលឯកឧត្តម **ហុង សុហួរ** និង ឯកឧត្តម **ស៊ូ សុជាតិ** បានរាយការណ៍, ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនសំដៅពន្លឿន និង ពង្រឹងការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា ដូចខាងក្រោម៖

**ទី១.** បន្តបង្កើនការផ្សព្វផ្សាយឱ្យបានទូលំទូលាយបន្ថែមទៀត តាមរយៈយន្តការ និង មធ្យោបាយថ្មីៗនៃបច្ចេកវិទ្យា អំពីអត្ថប្រយោជន៍ទាំងឡាយដែលរាជរដ្ឋាភិបាលកម្ពុជាបាន និង កំពុងផ្តល់ឱ្យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ជាពិសេស ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់វិស័យមូលបត្រ និង ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុនដែលបោះផ្សាយ និង ចុះបញ្ជីលក់មូលបត្រជាសាធារណៈ ។

**ទី២.** ពិនិត្យ និង ចាប់យកនូវកាលានុវត្តភាពថ្មីនៃប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីពន្លឿនការអភិវឌ្ឍទីផ្សារ តាមរយៈការធ្វើឌីជីថលភាវូនីយកម្មលើយន្តការរបស់ទីផ្សារមូលបត្រកម្ពុជា និង របស់និយ័តករមូលបត្រកម្ពុជា សំដៅផ្តល់ភាពងាយស្រួល និង ភាពឆាប់រហ័ស តែអាចគ្រប់គ្រងបាន សម្រាប់វិនិយោគិន និង ក្រុមហ៊ុនចុះបញ្ជី ព្រមទាំងការក្តាប់យកឱកាសនៃការអភិវឌ្ឍលឿននៃប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការធ្វើពិពិធកម្ម

ផលិតផលហិរញ្ញវត្ថុសម្រាប់ទីផ្សារ និង ការពង្រីកសេវាកម្មរបស់ផ្សារមូលបត្រកម្ពុជា ទៅក្រុមហ៊ុនមិនទាន់ចុះបញ្ជីផងដែរ ដូចជាយន្តការរក្សាទុកមូលបត្រជាដើម ។

**ទី៣.** គិតគូររៀបចំជាមួយគ្រប់តួអង្គពាក់ព័ន្ធទាំងអស់នៃទីផ្សារមូលបត្រ នូវសកម្មភាពលម្អិត ក្នុងបរិការណ៍នៃស្ថានភាពសេដ្ឋកិច្ចសកលបច្ចុប្បន្ន ព្រមទាំងស្ថានភាពវិវត្តលឿននៃបច្ចេកវិទ្យាហិរញ្ញវត្ថុនេះ សម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រ ១០ ឆ្នាំទៅមុខទៀត តាមរយៈការរៀបចំ និង ការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមូលបត្ររយៈពេល ១០ ឆ្នាំ ដែលខ្ញុំបានណែនាំរួចហើយទៅនិយ័តករមូលបត្រកម្ពុជា ឱ្យដឹកនាំរៀបចំការងារនេះ ។

ជាមួយគ្នានេះ, ខ្ញុំសូមស្នើឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា ដឹកនាំសម្របសម្រួលជាមួយគ្រប់តួអង្គពាក់ព័ន្ធ និង យកចិត្តទុកដាក់លើចំណុចដែលខ្ញុំបានលើកឡើងខាងលើនេះ ដើម្បីធ្វើឱ្យឃើញប្រត្យក្សនៃការរីកលូតលាស់ខ្លាំងក្លានៃផ្សារមូលបត្រកម្ពុជាក្នុងរយៈពេល ១០ ឆ្នាំខាងមុខនេះ ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី!

ការអភិវឌ្ឍវិស័យមូលបត្រទាមទារនូវពេលវេលា និង ការចូលរួមពីគ្រប់តួអង្គទាំងអស់, ទាំងវិស័យសាធារណៈ និង វិស័យឯកជន, ដូច្នេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រប់តួអង្គទាំងអស់នឹងសហការជាមួយផ្សារមូលបត្រកម្ពុជា និង និយ័តករមូលបត្រកម្ពុជាក្នុងការជំរុញការអភិវឌ្ឍទីផ្សារនេះជាបន្តទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីផ្សារ ព្រមទាំងច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក, លោកស្រី ជាថ្នាក់ដឹកនាំ, តំណាងក្រុមហ៊ុនពាក់ព័ន្ធទាំងអស់, ធុរជន និង វិនិយោគិនទីផ្សារ ដែលបានអញ្ជើញចូលរួមក្នុងសន្និសីទនាពេលនេះ ។

ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និង បុគ្គលិកទាំងអស់របស់ផ្សារមូលបត្រកម្ពុជា ព្រមទាំងពីនិយ័តករមូលបត្រកម្ពុជា ដែលបានសហការរៀបចំសន្និសីទស្តីពីទីផ្សារមូលបត្រកម្ពុជានេះឡើង ស្របពេលនៃខួប ១០ ឆ្នាំនៃដំណើរ-ការផ្សារមូលបត្រកម្ពុជារបស់យើង ។

ខ្ញុំសូមជូនពរឱ្យសន្និសីទរយៈពេលបីថ្ងៃនេះ ប្រព្រឹត្តទៅដោយជោគជ័យ ដើម្បីប្រមូលបាននូវធាតុចូលជាយុទ្ធសាស្ត្រថ្មីៗ និង សូមជូនពរឱ្យផ្សារមូលបត្រកម្ពុជា កាន់តែរីកចម្រើនទៅមុខ ដោយទទួលបានទំនុកចិត្តខ្ពស់ពីសំណាក់វិនិយោគិន, ទាំងក្នុង និង ក្រៅប្រទេស ។ ទន្ទឹមនេះ, ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, លោកឧកញ៉ា, លោក និង លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងពិធីនេះផ្ទាល់ ក៏ដូចជាអ្នកដែលចូលរួមតាមប្រព័ន្ធអនឡាញ, សូមទទួលបាននូវសុខភាពល្អបរិបូរណ៍, មានសុភមង្គលក្នុងក្រុមគ្រួសារ, ជួបប្រទះតែសេចក្តីសុខ និង សេចក្តីចម្រើនគ្រប់ប្រការ ជាពិសេស ជៀសផុតពីជំងឺកូវីដ-១៩ ។

ខ្ញុំសូមប្រកាសបើកសន្និសីទជាតិស្តីពីទីផ្សារមូលបត្រកម្ពុជា ក្រោមប្រធានបទ **«មួយទស្សវត្សរ៍នៃការអភិវឌ្ឍទីផ្សារមូលបត្រកម្ពុជា និង ដំណើរឆ្ពោះទៅមុខ»** ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!